ព័ត៌មានអំពី

# ជំងឺអុតស្វា

## តើអ្វីទៅជាជំងឺអុតស្វា?

ជំងឺអុតស្វាជាជំងឺឆ្លងដ៏កំរ បង្ករឡើយដោយមេរោគអុតស្វា។ វាជាប្រភេទមេរោគដែលស្ថិតនោះក្នុងក្រុមមេរោគអរតូដក (orthodox viruses) ដែលរួមមានមេរោគអុតស្វាយ និងមេរោគអុតគោ។

## តើមនុស្សឆ្លងជំងឺអុតស្វាតាមរយៈអ្វី?

ជំងឺអុតស្វាអាចឆ្លងពីសត្វទៅមនុស្ស ឬ ពីមនុស្សទៅមនុស្ស ។ អ្នកអាចឆ្លងជំងឺអុតស្វាតាមរយៈការប៉ះផ្ទាល់ទៅនឹងសារធាតុរាវនៅលើរាងកាយ ឬដំបៅ ឬការប៉ះវត្ថុដែលអាចឆ្លងបាន ដូចជា សំលៀកបំពាក់ ឬគ្រឿងក្រណាត់ ។ ជំងឺនេះក៏អាចឆ្លងតាមរយៈតំណក់ទឹកតាមផ្លូវដង្ហើម ដោយការនៅទល់មុខគ្នារយៈពេលយូរ (លើសពី៣ម៉ោង)។ លើសពីនេះទៀត អ្នកដែលមានផ្ទៃពោះ ក៏អាចចម្លងមេរោគនេះទៅទារកក្នុងផ្ទៃផងដែរ តាមរយៈទងសុក។

## តើអ្នកណាងាយនឹងឆ្លងជំងឺអុតស្វា?

អ្នកណាក៏អាចឆ្លងជំងឺអុតស្វាបានដែរ ។ ប៉ុន្តែ  អ្នកដែលស្ថិតក្នុងប្រភេទខាងក្រោមមានឱកាសងាយនឹងឆ្លង៖

- អ្នកដែលបានធ្វើដំណើរទៅតំបន់ដែលមានករណីជំងឺអុតស្វា ឬមានការឆ្លងជំងឺនោះ
- អ្នកដែលបានប៉ះពាល់ជាមួយអ្នកដែលមានចេញអាការៈអុតស្វា ឬបានពិនិត្យឃើញថាមានជំងឺអុតស្វា
- ដោយមានការចេញករណីជំងឺអុតស្វាក្នុងខែឧសភា ឆ្នាំ២០២២  អ្នកដែលបញ្ជាក់ខ្លួនឯងថាជាបុរសហើយមានទំនាក់ទំនងជិតស្និទ្ធជាមួយមនុស្សប្រុសដូចគ្នា  មានឱកាសងាយនឹងឆ្លងជំងឺនេះ ។

## តើអាការៈជំងឺអុតស្វាមានអ្វីខ្លះ?

ជាទូទៅ  អ្នកដែលឆ្លងជំងឺអុតស្វា អាចនឹងមានអាការៈ៖

- គ្រុនក្តៅ អស់កំលាំង និងអាការៈនានាស្រដៀងនឹងគ្រុនផ្តាសាយ (រងា ឈឺក្បាល ឈឺសាច់ដុំ ឡើងកូនកណ្តុរ) ។ ពេលខ្លះ អាចនឹងមិនមានអាការៈស្រដៀងនឹងគ្រុនផ្តាសាយ ឬក៏អាចមានចេញអាការៈនេះក្នុងកំរិតស្រាល ។
- កន្ទួលរមាស់ ដែលអាចក្លាយទៅជាដំបៅ ឬកមរមាស់ (រូបភាព) ហើយឆ្លងពីមាត់ និង មុខ ទៅកន្លែងផ្សេងទៀត។ ពេលខ្លះ កន្ទួលរោល និងដំបៅ កើតតែនៅកន្លែងអវយវៈភេទតែប៉ុណ្ណោះ។







LONG BEACH
HEALTH & HUMAN SERVICES

ផ្នែក គ្រប់គ្រង និងតាមដាន ជំងឺឆ្លង
2525 Grand Avenue, Long Beach, CA 90815 I Phone: (562) 570-4302
Website: longbeach.gov/mpox

# ព័ត៌មានអំពី
# ជំងឺអុតស្វា

## តើអ្នកអាចការពារខ្លួនពីជំងឺអុតស្វាបានយ៉ាងដូចម្តេច?

ថ្នាំវ៉ាក់សាំងការពារជំងឺអុតស្វាយក៏ជួយផ្តល់ការការពារចំពោះជំងឺអុតស្វាផងដែរ ។ ប៉ុន្តែ យើងណែនាំផ្តល់ជូនចំពោះអ្នកដែលងាយនឹងឆ្លងជំងឺនេះតែប៉ុណ្ណោះ ។ សូមជួយការពារខ្លួនអ្នកពីការឆ្លងជំងឺអុតស្វា ដោយ៖

- លាងដៃជាមួយសាប៊ូ និងទឹក ឬប្រើទឹកអាល់កុលលាងដៃ
- ជៀសវាងការប៉ះពាល់ជាមួយសត្វដែលនាំចូលពីក្រៅប្រទេស ជាពិសេស សត្វដែលឈឺ ឬសត្វងាប់។
- ជៀសវាងការប៉ះគ្រឿងដំណេក ឬសំលៀកបំពាក់ ដែលអាចចម្លងមេរោគនេះ
- ជៀសវាងការប៉ះកន្ទួលរមាស់ ឬកមរមាស់ របស់អ្នកដែលមានជំងឺអុតស្វា
- ប្រើប្រាស់ឧបករណ៍ពាក់ការពារខ្លួន (PPE) នៅពេលថែរក្សាអ្នកដែលកើតជំងឺអុតស្វា
- ជៀសវាងធ្វើដំណើរទៅទីកន្លែងដែលមានករណីឆ្លងជំងឺនេះ
- ជៀសវាងរាល់សកម្មភាពនានាដែលអាចធ្វើអោយឆ្លងជំងឺអុតស្វាបាន ដូចជា ការរួមរក្ស ការថើប ការអោប ឬការប្រឡែងលេងជាមួយមនុស្សច្រើន ឬអ្នកមិនស្គាល់ ។

## តើជំងឺអុតស្វាត្រូវបានវិភាគយ៉ាងដូចម្តេច?

ជំងឺអុតស្វាត្រូវបានវិភាគក្នុងមន្ទីពិសោធន៍ដោយធ្វើតេស្តយកសំណាកពីដំបៅ ។ អ្នកដែលមានចេញរោគសញ្ញាណាមួយរបស់ជំងឺអុតស្វាត្រូវទាក់ទងទៅគ្រូពេទ្យប្រចាំខ្លួន។

## តើជំងឺអុតស្វាអាចព្យាបាលបានជាឬទេ?

មនុស្សមួយចំនួនធំនឹងជាសះស្បើយដោយខ្លួនឯង ប៉ុន្តែអ្នកដែលមានប្រព័ន្ធការពាររាងកាយខ្សោយ អាចនឹងមានជំងឺធ្ងន់ធ្ងរ ។ បច្ចុប្បន្ន មិនទាន់មានការព្យាបាលច្បាស់លាស់សំរាប់ជំងឺអុតស្វា នៅឡើយទេ ។ ថ្នាំបំបាត់មេរោគពីក្នុងខ្លួនអាចជួយសម្រាលជំងឺធ្ងន់ធ្ងរបាន ។

## សំរាប់ព័ត៌មានបន្ថែម

នាយកដ្ឋានសុខាភិបាល នៃទីក្រុងឡុងប៊ិច

ក្រសួងសុខាភិបាលសាធារណៈ របស់រដ្ឋកាលីហ្វរញ៉ា

មជ្ឈមណ្ឌលគ្រប់គ្រង និងការពារជំងឺឆ្លង (CDC)

## ប្រភពព័ត៌មាន


- *Photo credit: UK Health Security Agency*
- *Monkeypox*. Centers for Disease Control and Prevention. (2022, May 20). Retrieved May 25, 2022, from https://www.cdc.gov/poxvirus/monkeypox/
- *2022 United States Monkeypox Case.* Centers for Disease Control and Prevention. (2022, May 24). Retrieved May 25, 2022, from https://www.cdc.gov/poxvirus/monkeypox/response/2022/index.html?CDC_AA_refVal=https%3A%2F%2Fwww.cdc.gov%2Fpoxvirus%2Fmonkeypox%2Foutbreak%2Fcurrent.html
- *Figure 2 skin and soft tissue manifestations of monkeypox*. (2022, May 24). [Photograph]. The Lancet Infection Diseases. https://doi.org/10.1016/S1473-3099(22)00228-6



LONGBEACH HEALTH & HUMAN SERVICES

ផ្នែក គ្រប់គ្រង និងតាមដាន ជំងឺឆ្លង

2525 Grand Avenue, Long Beach, CA 90815 I Phone: (562) 570-4302

Website: longbeach.gov/mpox